# ៣

## ថៃជន្យ ឬ ព្រលខាសនា

ព្រឹកស្អែកឡើង ខ្ញុំបានទៅកំពង់ផែ ទាក់ទងជាមួយពួកកម្មករ ហើយបានទទួលរួមរកស៊ីលីសែងជាមួយអ្នកទាំងនោះ ។ កិច្ចការនេះឥតចោទបញ្ហាពិបាកចំពោះខ្ញុំទេ ។ ព្រោះខ្ញុំធ្លាប់ធាប់ឃុំឃាំង និង ធ្លាប់ធ្វើការធ្ងន់អស់ជាច្រើនឆ្នាំមកហើយ ។

ថ្ងៃមួយ ខ្ញុំលីបាវសណ្ដែកទន្ធន់ប្រហែលមួយរយគីឡូក្រាមឡើងពីកំពង់ផែទៅលើមាត់ច្រាំង ។ ក្នុងខណៈដែលខ្ញុំកំពុងតែប្រឹងទប់ខ្លួនពោះជំហានល្អតាមក្ដារស្ពាននោះ មានកម្មករជាតិខ្មែរម្នាក់ស្រែកឡើងៈ

- យី ! ឡាវឥឡូវនេះ លីបានធ្ងន់ៗណាស់ទៀ ! ( ពួកកម្មករជាតិខ្មែរ គេអត់ស្គាល់ឈ្មោះខ្ញុំទេ . . . ប៉ុន្តែដឹងថាខ្ញុំជាជនជាតិឡាវ ដូច្នេះគេចេះតែហៅខ្ញុំថាឡាវៗគ្រប់គ្នា )

ដូច្នោះ មិត្តកម្មករម្នាក់ទៀតស្រែកបន្ទរ

-ប៉ុន្មានថ្ងៃនេះ មិត្តឡាវនេះ ស្រាប់តែអាចលីបាវសណ្ដែកបាន ! . . .

ពេលទម្លាក់បាវសណ្ដែករួចហើយ ខ្ញុំលើកដៃជូតញើស ដើរចុះ



ទៅវិញ ក៏ជួបនឹងហ្វូងកម្មករប្រាំនាក់កំពុងអង្គុយសំរាក ។ គ្រាន់តែឃើញខ្ញុំភ្លាម ពួកគេស្រែកហៅរាក់ទាក់ ៖

- អើ . . .មិត្តឡាវមកសំរាកជក់បារីសិន ! . . .

តាមការពិត ពួកកម្មករលីសែងនៅកំពង់ផែទាំងអស់ គេស្រឡាញ់រាប់អានខ្ញុំគ្រប់គ្នា ព្រោះឃើញខ្ញុំស្លូតបូត និង សុចរិតត្រឹមត្រូវ ។ ខណៈដែលមិត្តកម្មករខ្មែរស្រែកហៅខ្ញុំនោះ ស្រាប់តែនារីម្នាក់ដែលអង្គុយបោកខោអាវនៅលើក្បាលទូកធំមួយជិតផែ ងើបមុខសម្លឹងមើលខ្ញុំយ៉ាងយកចិត្តទុកដាក់ ។ ទន្ទឹមពេលនោះ ខ្ញុំងាកមើលទៅដែរ ខ្សែភ្នែកទាំងពីរប៉ះគ្នា ធ្វើឱ្យខ្ញុំមានអារម្មណ៍ច្រួលច្របល់យ៉ាងចម្លែក ហើយនាងក៏ឈ្ងោកមុខចុះវិញភ្លាមដែរ ។

ខ្ញុំអង្គុយនិយាយលេងជាមួយបងប្អូនកម្មករជុំគ្នា ប៉ុន្តែមិនដឹងជាមានកម្លាំងអ្វីស្រូបទាញ បានជាធ្វើឱ្យខ្ញុំចេះតែងាកទៅមើលនាងឥតឈប់ ។

មួយសន្ទុះនាងងើបមុខលបមើលខ្ញុំម្ដងទៀត លុះប្រទះឃើញខ្ញុំសម្លឹងនាងស្ទើរភ្លឹកយ៉ាងនេះ នារីរូបស្អាតក៏ឈ្ងោកមុខម្ដងទៀតដោយអាការៈញញឹមអៀនប្រៀន ។

បន្ទាប់ពីសំរាកមួយសន្ទុះ ខ្ញុំក៏ចុះទៅក្នុងកប៉ាល់ ហើយលីបាវសណ្ដែកឡើងទៅលើមាត់ច្រាំងបន្តទៅទៀត ។ គ្រាន់តែទម្លាក់បាវទៅលើគំនរភ្លាម ស្រាប់តែមានស្ត្រីចំណាស់ម្នាក់យួរកន្ត្រកធំមួយ ដែលមានអីវ៉ាន់ពេញដើរចូលមកជិតខ្ញុំ ហើយប្រាប់ ៖

- ក្មួយជួយលីការ៉ុងអង្ករនោះចុះទៅក្នុងទូកឲ្យមីងបន្តិច ( គាត់និយាយព្រមទាំងចង្អុលទៅការ៉ុងអង្ករចំនួនប្រហែលពីរតៅនៅលើស្ពានក្បែរនោះ ) ។

ខ្ញុំដើរចេញពីស្ពានបណ្ដើរ ឆ្លើយបណ្ដើរ ៖

- បាទ ទូករបស់មីងមួយណា ?

- ហ៊ឺ ដើរតាមមីងមក . . .

ខ្ញុំលើកការ៉ុងអង្ករលី ហើយដើរចុះជណ្ដើរចំណោតច្រាំងតាមគាត់ពីក្រោយ ។ លុះចុះដល់ផែ គាត់ក៏ឆ្លងតាមស្ពានក្ដារចូលទៅក្នុងទូកធំមួយមានដំបូល គឺទូកដែលមានយុវនារីកំពុងតែបោកខោអាវនោះ ។

ឃើញស្ត្រីចំណាស់ចូលដល់ នាងក្រមុំក៏ឈប់ទទួលកន្ត្រកពីដៃទាំងពោលដោយរីករាយ ៖

- ម៉ែមកពីផ្សារវិញហើយទេតើ ខ្ញុំក៏ទាន់ដាំបាយផង ! . . .

- អើ . . .មិនទាន់ថ្ងៃណាស់ណាទេ . . . ( ស្ត្រីចំណាស់ឆ្លើយ)

ពេលនេះ មិនបាច់អ្នកណាប្រាប់ ក៏ខ្ញុំដឹងដែរថា ស្ត្រីនេះជាម្ចាស់ទូក ហើយនារីរូបស្អាតដែលលបមើលខ្ញុំហ្នឹង ជាកូនក្រមុំរបស់គាត់ ។ បន្ទាប់ពីប្រាប់កន្លែងឲ្យខ្ញុំដាក់ការ៉ុងអង្ករួចហើយ គាត់ក៏លូកដៃទៅក្នុងហោប៉ៅអាវហើយសួរ ៖

- យកឈ្នួលប៉ុន្មានក្មួយ ! . . .

- មិនអីទេមីង ខ្ញុំមិនយកប្រាក់ឈ្នួលទេ ( ខ្ញុំគ្រវីក្បាលប្រកែក )

ស្ត្រីម្ចាស់ទូកបើកភ្នែកធំៗ ៖



- អ្ហា ! ម៉េចក៏ក្មួយមិនយកឈ្នួលអីចឹង ? . . .

- ព្រោះអង្ករបស់មីងតិចពេក អត់ធ្ងន់ផង . . . ចាត់ទុកដូចជាខ្ញុំជួយមីងមួយដៃម្ដងចុះ . . .

តាមការពិតពាក្យសំដីរបស់ខ្ញុំគឺចេញមកដោយស្មោះត្រង់ពីចិត្តពិតៗ . . . ព្រោះខ្ញុំយល់ថា អង្ករមួយកំណាត់ការ៉ុងនេះ វាតិចតួចកំប៉ុកណាស់ ។ ហើយបើខ្ញុំមិនជួយលើឲ្យគាត់ ក៏គង់តែខ្ញុំដើរចុះពីលើច្រាំងមកតាមផ្លូវវិញដែរ . . . ។ ឮពាក្យប្រកែករបស់ខ្ញុំ មីងម្ចាស់ទូកនៅស្ងៀម បើកភ្នែកធំៗ សម្លឹងមុខខ្ញុំ ដោយងឿងឆ្ងល់ ។ ខណៈនោះ កូនក្រមុំរបស់គាត់លួចសម្លឹងមុខខ្ញុំញញឹម ហើយងាកទៅតាន់ម្ដាយ ៖

- គាត់ជាជនជាតិឡាវណ៎ាម៉ែ ! . . .

ឮសំដីរបស់កូនក្រមុំ ស្ត្រីម្ចាស់ទូកសើចស្រស់ស្រាយ ហើយសួរមកខ្ញុំជាភាសាឡាវភ្លាម ៖

- ក្មួយឈ្មោះអី ! . .

- បាទ ! . . ខ្ញុំឈ្មោះ បួផាន់ ស៊ីវ៉ាន់កង់ ( ខ្ញុំប្រាប់ត្រង់ )

ដោយការសន្ទនាទៅក្នុងពេលដ៏តិចតួច ខ្ញុំក៏ប្រញាប់លាម្ចាស់ទូកទៅធ្វើការវិញ ព្រោះខ្ញុំមិនចង់ឲ្យបានប្រាក់តិចជាងកម្មករឯទៀតនោះទេ ! . . . ។

លុះពេលថ្ងៃត្រង់ ខ្ញុំនិងកម្មករទាំងអស់ត្រូវសម្រាក ដើម្បីអាស្រ័យបាយ ។ ខ្ញុំចុះទៅបួតទឹកសំអាតកាយនៅក្រោមផែ រួចហើយស្លៀកពាក់ចុងឡើងទៅផ្សារ ស្រាប់តែឃើញនារីដែលបោកខោអាវពីព្រឹកមិញ

ចេញមកក្បាលទូក ស្រែកហៅខ្ញុំទាំងញញឹមពព្រាយ ៖

- ពុក ខ្ញុំសូមអញ្ជើញបងមកពិសាបាយ ជាមួយនឹងគ្រួសារខ្ញុំមួយពេល . . .

ខ្ញុំភ្ញាក់ផ្អើល ព្រោះមិនដឹកស្មានថា នារីនេះចេះភាសាឡាវផង សោះ មិនដឹងជាតុកឡាយនាងជាជនជាតិឡាវ ឬ ជាជនជាតិខ្មែរ ។ ប៉ុន្តែ គួរឲ្យជឿងឆ្ងល់ជាទីបំផុតនោះ គឺខ្ញុំពុំដែលស្គាល់គាត់សោះ ទើបនិយាយ រកគ្នាប្អូនស្មម៉ាត់ក្នុងពេលល្ងាចម្សិលមិញ ហេតុអីបានជាគាត់ចិត្តល្អហៅ ទៅហូបបាយទឹកជាមួយយ៉ាងនេះ ?

ឃើញខ្ញុំនេះអញ្ញាញញើតញញើម នាងក្រមុំតឿនថែម ៖

- អញ្ជើញឡើងមក ពុកម៉ែខ្ញុំកំពុងរង់ចាំផងបង ! . . .

ពាក្យសំដីចុងក្រោយនេះ ធ្វើឲ្យខ្ញុំពុំអាចបោះបង់ប្រកែកបាន ណាមួយដោយចង់ក្សាភាពអង់អាចរបស់បុរសភេទផង ខ្ញុំក៏សើចងក់ក្បាល សំដែងការគួរសម ហើយដើរស្ទាបស្ទង់ក្តារឆ្លងទៅទូករបស់នាងភ្លាម។

ទូកនេះធំលើសទូកនានា ដែលចតនៅម្តុំនោះ ដំបូលជិតគត់មត់ ល្អមិនមានជញ្ជាំងខណ្ឌកណ្តាលចែកជាពីរល្វែង ហើយក្តារកំរាលរលោង ស្រិលស្អាត ដូចក្នុងផ្ទះមួយតូច ។

ចូលទៅដល់ក្នុងទូក ឃើញបុរសចំណាស់ម្នាក់អាយុខ្ទង់សែសិបឆ្នាំ និងស្ត្រីម្ចាស់ទូកដែលខ្ញុំធ្លាប់ស្គាល់ម្តងហើយនោះ នៅអង្គុយចរៀបចំជា ស្រេចបែប ។ នោះគ្មាននរណាប្រាប់ ក៏ខ្ញុំកាត់យល់ថា បុរសចំណាស់ នេះ ជាឪពុករបស់នារីរូបស្អាតនោះ ។



ខ្ញុំលើកដៃសំពះជំរាបសួរយ៉ាងនបនោទាន ហើយប្តីប្រពន្ធម្ចាស់ទូក ក៏សើចញញឹមទទួលរាក់ទាក់វិញដែរ ។ បន្ទាប់ពីខ្ញុំអង្គុយបត់ជើងទល់មុខ គាត់ មីងម្ចាស់ទូកឡើងជាំងចាក់ទឹកតែក្តៅហុយ ៗ ដាក់ពែងបី ហើយ លើកមួយពែងហុចឲ្យខ្ញុំ :

- ពិសាទឹកតែសិនទៅក្មួយ ! . . .

- បាទ អរគុណមីង (ខ្ញុំឆ្លើយព្រមទាំងលូកដៃទទួលដោយគោរព )

ពូម្ចាស់ទូកសម្លឹងខ្ញុំតាំងពីក្បាលដល់ចុងជើងយ៉ាងពិនិត្យពិច័យ ទើប សួរ ៖

- ឮថាក្មួយមានសញ្ជាតិជាឡាវឬ ? . . .

- បាទ ? . . .

- ជនជាតិអី ?

- បាទ ! . . . ជនជាតិខ្មែរ !

- នៅខេត្តណា ? . . .

- បាទ . . . ខ្ញុំកើតនៅខាងចលោកពូ ! . . .

- ក្មួយឈ្មោះអី អាយុប៉ុន្មាន ? . . .

- បាទ ! ឈ្មោះបូផាន់ស៊ីវ៉ាន់ធន់ ឆ្នាំនេះអាយុម្ភៃហើយពូ ! . . .

បុរសម្ចាស់ទូកលើកទឹកតែក្រេប :

- ខ្ញុំឮកូនមាលាថា មានកម្មករកស៊ីលីសែងនៅកំពង់ផែម្នាក់ជា ឡាវ ទើបពូចង់ស្គាល់និងចង់ដឹងថា ហេតុអីក្មួយមកដល់ទីនេះ ព្រោះនៅ ភ្នំពេញ ពួកឡាវពុំសូវប្រទះឡើយទេ ! . . .

ខ្ញុំត្រិះរិះបន្តិច ទើបដាច់ចិត្តសួរ ព្រោះឃើញម្ចាស់ទូកនិយាយភាសាឡាវច្បាស់ និងស្ទាត់ជំនាញជាងប្រពន្ធ និងកូនក្រមុំ :

- សូមអភ័យទោស ពូជាជនជាតិឡាវដែរឬ ? . . .

- ទេ ! . . ពូជាខ្មែរទេ ប៉ុន្តែស្រុកកំណើតរបស់ពូនៅខេត្តស្ទឹងត្រែង ទើបពូចេះនិយាយភាសាឡាវ ។ ឯប្រពន្ធខ្ញុំនេះ ស្រុកនៅក្រចេះ កូនមាលានេះក៏វាធ្លាប់រស់នៅក្រចេះពីតូចមកដែរ ដូច្នេះហើយទើបវាចេះនិយាយភាសាឡាវខ្លះ ។ . . .

មកដល់ពេលនេះ ទើបខ្ញុំដឹងថា នារីរូបស្អាតជាកូនក្រមុំរបស់គាត់ ឈ្មោះ មាលា ហើយលែងងឿងឆ្ងល់ចំពោះសមាជិកគ្រួសារនេះ ដែលចេះឡាវគ្រប់គ្នា ព្រោះខេត្តកំណើតរបស់គាត់គឺខេត្តស្ទឹងត្រែងនោះ មានព្រំប្រទល់ជាប់នឹងខេត្ត ចំប៉ាសាក់របស់ប្រទេសឡាវ ។ នៅស្ទឹងត្រែងមានជនជាតិឡាវរស់នៅច្រើនណាស់ ! . . .

ខ្ញុំលើកពែងស្រេបបន្តិចទើបពោល ៖

- នៅភ្នំពេញនេះ ខ្ញុំគ្មានស្គាល់អ្នកណាម្នាក់សោះ ហើយពុំដែលបានជួបនឹងឡាវផង ដូច្នេះពេលនេះបានស្គាល់គ្រួសារពូ ធ្វើឲ្យខ្ញុំសប្បាយរីករាយ និងមានការកក់ក្តៅណាស់ ! . . .

ពូម្ចាស់ទូកសើចតិច ៗ សម្លឹងមុខខ្ញុំដោយពន្លឺភ្នែកអាណិតអាសូរ ទើបសួរទន់ភ្លន់ ៖

- បើក្មួយឥតមានបងប្អូន ហើយគ្មានស្គាល់អ្នកណាសោះ ហេតុអ្វីបានជាក្មួយមកកាន់ភ្នំពេញនេះ ?



ខ្ញុំនឹកអាណិតក្នុងចិត្តជាខ្លាំង ព្រោះបើប្រាប់ត្រង់ថាខ្ញុំជាមនុស្សទើបនឹងចេញពីពន្ធនាគារ ហាក់ដូចជាមានការអៀនខ្មាសខ្លាំងណាស់ ហើយជួនកាលបន្ទាប់ពីបានដឹងការពិត ប្រហែលជាប្តីប្រពន្ធម្ចាស់ទូកព្រមទាំងកូនក្រមុំមើលងាយ ហើយឈប់រាប់អានផងក៏មិនដឹង ! ប៉ុន្តែបើភូតកុហកគាត់ ហាក់ដូចជាក្បត់នឹងសតិសម្បជញ្ញៈខ្លួនឯង ។ លុះទីបំផុត ខ្ញុំសម្រេចចិត្តរៀបរាប់ពីប្រវត្តិដ៏ជូរចត់របស់ខ្ញុំប្រាប់គាត់ដោយត្រង់ ។ តាំងពីដើមដល់ចប់ ។

បានដឹងហើយ ប្តីប្រពន្ធម្ចាស់ទូកទាំងពីរនាក់លួចមើលមុខគ្នា ហាក់សញ្ជឹងគិតគតចេញស្តី ។ មួយសន្ទុះ ទើបអ្នកស្រីជាភរិយាស្រែកហៅកូនជាភាសាកម្ពុជា ហើយពួកនាងមាលាឆ្លើយតបពីក្នុងរោងសំឡេងស្រួយស្រទន់ព្រមទាំងដើរចេញមក ដោយលើកស្លាកចានដែលមានម្ហូបក្តៅហុយមកផង ! . . .

ប្តីប្រពន្ធម្ចាស់ទូកបានអញ្ជើញខ្ញុំ ឲ្យរាស្រ័យបាយជាមួយនឹងគាត់ និងនាងមាលា គេចចូលទៅក្នុងវិញបាត់ភ្លាម ។ ដោយឃើញអាកប្ប-កិរិយារបស់ប្តីប្រពន្ធម្ចាស់ទូកស្លូតស្លៀមខុសពីពេលដែលខ្ញុំទើបនឹងមកដល់ដំបូង ខ្ញុំមានការពិបាកចិត្តណាស់ ព្រោះមិនដឹងជាគាត់គិតគាត់យល់បែបណា ចំពោះប្រវត្តិរបស់ខ្ញុំ . . .

ខ្ញុំស្លុតក្នុងសភាពការណ៍ដូចជាមនុស្សជិះលើខ្នងខ្លាអីចឹង នៅក៏ពុំស្រួលចុះក៏ពុំសុខ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ខ្ញុំខំកាត់ក្តីអៀនខ្មាសបរិភោគជាមួយនឹងគេទាំងទើសទាល់ ។

បន្ទាប់ពីបរិភោគបាយរួចហើយ មាលាចេញមកលើកចានឆ្នាំងទៅ

ក្រោយវិញអស់ ស្រាប់តែពូម្ចាស់ទូកញញឹមស្រស់ស្រាយវិញ ទាញកញ្ចប់ថ្នាំមកជាត់ឲ្យខ្ញុំ ព្រមទាំងម្ហូបផងក៏ខ្លួនឯង ទើបរៀបរាប់ប្រាប់ :

- ខ្ញុំឈ្មោះ រ៉ុស ជម៉ែវានេះឈ្មោះហែម ។ សព្វថ្ងៃមានកូនពីរនាក់ គឺតូចនេះច្បងគេ ឯអាប្រុសប្អូនឈ្មោះហ៊ិននៅចាំផ្ទះឯណោះ ! . . .

ខ្ញុំទន្ទឹកពាក្យនិយាយសាកសួរគាត់ :

- ផ្ទះរបស់ពូនៅឯណាទៅ ?

មីងហែមដែលនៅស្ងៀមស្ងាត់យូរមកហើយនោះ ក៏លូកមាត់ចូលដែរ :

- ផ្ទះរបស់មីងនៅក្រោមចង្វា ប៉ុន្តែមីងយកត្រីមកលក់នៅកំពង់ផែនេះរាល់ថ្ងៃ មិនសូវដែលនៅផ្ទះទេ មីងអាណិតអាសូរក្មួយណាស់ ដែលរសាត់អណ្តែតត្រសែតត្រមង់ត្រមោចតែម្នាក់ឯងមកស្រុកឆ្ងាយយ៉ាងនេះ ពេលណាក្មួយឃើញទូកមីងចូលចត មកលេងចុះ ចង់បានត្រីហូបក៏មិនខ្វះដែរ ! . .

មកដល់ពេលនេះ ទើបខ្ញុំយល់ចិត្តម្ចាស់ផ្ទះ ។ អម្បាញ់មិញពេលដែលគាត់ទាំងពីរនាក់មានអាការៈស្ងាត់ស្ងៀមមិនស្តីនិយាយ មិនមែនមកពីគាត់មានគំនិតស្អប់ខ្ពើមខ្ញុំទេ ផ្ទុយទៅវិញគឺគាត់ថ្លោលចិត្តអាណិតអាសូរខ្ញុំសោះ . . .

ខ្ញុំប្រញាប់ថ្លែងអំណរគុណដោយស្មោះចំពោះគាត់ :

- ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកពូ និងអ្នកមីងដែលមានចិត្តមេត្តាចំពោះខ្ញុំដែលជាមនុស្សអាវ៉ាសែរបៀបនេះ ! . . .



ពូរ៉ុស បង្ហុយផ្សែងបារីទោល ហើយងាកមកកាន់ខ្ញុំ :

- ចរិតខ្មែរ គឺតែងតែអាណិតអាសូរចំពោះអ្នកកំសត់ទុរគតរីចឹង ! ក្មួយកុំអៀនខ្មាសចំពោះមុខរបរក្មួយធ្វើអី ! . . . គ្មានមុខរបរណាដែលថោកទាបទេ កុំឲ្យតែយើងរកស៊ីលួចឆក់ប្លន់គេ ! . កាលពីក្មេង ពូក៏ធ្លាប់លំបាកលំបិនដូចក្មួយដែរ . . . ពូធ្លាប់អូសរ៉ឺម៉ក ធ្លាប់លីសែងនៅកំពង់ផែ ធ្លាប់ស៊ីឈ្នួលបំរើគេ រហូតដល់ចំណាស់នេះ ទើបពូកសាងជីវភាពគ្រួសារបានប៉ុណ្ណេះ ! . .

ពាក្យសំដីល្ហងលោមរបស់ម្ចាស់ទូក ធ្វើឲ្យខ្ញុំមានការកក់ក្តៅរលាយសេចក្តីអៀនខ្មាសអស់ជាច្រើន . . .

ក្នុងពេលដែលខ្ញុំអង្គុយនិយាយជាមួយនឹងឪពុកធាង មាលានេះតែលួចរអិលពីក្រោយជញ្ជាំងមើលខ្ញុំជាញឹកញយ . . ធាងមានរាងតូចច្រឡឹងខាប់ សក់វែងប្រះស្មា ភ្នែកខ្មៅក្រឹប ច្រមុះតូចស្រួចសមនឹងបបូរមាត់ សម្បុរស្រអែម តែក៏ឆ្លាតគួរឲ្យស្រឡាញ់ . . . ពេលនៃភ្នែកយើងប៉ះគ្នា ខ្ញុំទទួលអារម្មណ៍ហាក់ដូចរបេះដូងដើរខុសចង្វាក់ ហើយមានចំហាយក្តៅភាយរត់សព្វសព៌ាង្គកាយ ។

ដោយដឹងខ្លួនថា ខ្ញុំមានអារម្មណ៍វង្វេងវង្វាយ បារម្ភខ្លាចក្រែងនិយាយស្តីមានការខុសឆ្គង ខ្ញុំក៏ប្រញាប់លាម្ចាស់ទូកត្រឡប់មកវិញ . . .

តាំងពីថ្ងៃនោះ ឲ្យតែទូកចូលចតនៅកំពង់ផែ មាលាតែងស្រែកហៅខ្ញុំឲ្យទៅយកត្រីទទួលទាន ។ ដួនកាលប្តីប្រពន្ធម្ចាស់ទូកឃាត់ខ្ញុំឲ្យនៅរួមពេស្រ័យជាមួយផង ។ មិនយូរប៉ុន្មានការរាប់អានរវាងខ្ញុំ និង

ពូរីសកាន់តែជិតស្និទ្ធឡើង ។ រីឯម៉ាលាទិនខ្ញុំក៏ហ៊ាននិយាយចំអកចំអន់គ្នាទៅវិញទៅមកលែងខ្មាសអៀនដែរ ។ លើសពីនេះ ថ្ងៃណាដែលខ្ញុំបានឃើញទូកពូរីសយកត្រីមកលក់ទេ ខ្ញុំហាក់ដូចជាអផ្សុកយ៉ាងចម្លែក ។

*

*　　　*



# ៤

## ទឹកចិត្តអាថ៌កំបាំង

ប៉ុន្មានខែក្រោយមកទៀត នាយប់មួយក្នុងរដូវវស្សា រឿងចៃដន្យអាក្រក់មួយបានកើតឡើង ។

ពេលព្រលប់ណាស់ទៅហើយ មេឃងងឹតឈឹងគ្មានផ្កាយមួយគ្រាប់សោះ ផ្គរលាន់គ្រលាន់គគ្រឹម ជាសញ្ញាប្រាប់ថាជិតភ្លៀង ។ ខ្ញុំក្រាលកន្ទេលក្រោមសំយាបវិហាររួចហើយ ប៉ុន្តែពុំទាន់ហ៊ានចងមុងទេ ព្រោះខ្លាចភ្លៀងមកនាំតែពិបាកស្រាយវិញ ។

ក្នុងខណៈនោះ ស្រាប់តែមានសំឡេងមនុស្សជាច្រើនស្រែករ៉ូសៗសពីជើងភ្នំជាមួយនឹងពន្លឺភ្លើងពិលវាសវែងចន្ទាចព្រោងព្រាត ហើយឃើញស្រមោលខ្មៅមួយរត់លឿនស្ទើរពីចង្កេះភ្នំឡើងមក ។

ក្រោយពន្លឺផ្លេកបន្ទោរជាញឹកញាប់ ខ្ញុំឃើញស្រមោលខ្មៅរត់សំដៅចេតិយធំហាក់ដូចព្រាងគេចខ្លួនទៅទីនោះ ។ ប៉ុន្តែដោយមានផ្លេកបន្ទោរម្ដងទៀត ទើបគេមើលឃើញច្បាស់ ទើបឮសំឡេងពួកអ្នកដេញតាមនៅចង្កេះភ្នំស្រែកប្រាប់គ្នាឲ្យព័ទ្ធចេតិយ ។ ដឹងដូច្នោះ ស្រមោលខ្មៅហាក់ភ្លាត់ជំពិត គេក៏រត់សំដៅមករកព្រះវិហារវិញ ។

ដោយគំនិតប្រតិកម្មខ្ញុំយល់ថា ជនអ្នកដែលគេត្រូវដេញនោះច្បា
ជាជនទុច្ចរិត ដែលប្រព្រឹត្តអំពើលួចប្លន់មកពីណាជាមិនខាន ។ ខ្ញុំឈរ
តែបនឹងជញ្ជាំងព្រះវិហារ រង់ចាំឲ្យមនុស្សនោះរត់មកដល់ពីមុខ ក៏ប
ទៅចាប់ឱបតែម្តង ។ ដោយស្មានមិនដល់ថា មានអ្នកពួនស្ទាក់ចាំចា
គេតក់ស្លុតហួសឧបមា ប៉ុន្តែក្នុងពេលភិតភ័យរបៀបនេះ មនុស្សនេ
តែងមានកម្លាំងខ្លាំងក្លាលើសពីធម្មតា ។ ដូច្នេះហើយ បានជា
ស្រមោលខ្មៅរើបំរះទាល់តែរួច ហើយការប្រវាយប្រតប់គ្នាក៏កើតឡើ
ប្រទូលប្រទះក្លាម ។ ដោយសារទាល់ច្រក ដើម្បីរំដោះខ្លួន គូបដិ
ក៏ដកកាំបិតស្នៀតសស្អាតស្អុះមកចាក់ខ្ញុំយ៉ាងសាហាវមួយរំពេច ។
លោតគេចផុត ហើយស្រវាធៀកពីក្បាលដំណែកប្រាថ្នាតបវិញ ប៉ុ
ពេលនោះ ស្រាប់តែផ្ទេកបន្ទោរឬងទៀត ធ្វើឲ្យខ្ញុំភ្ញាក់ក្រញាង ហ្វេ
មើលស្គាល់មនុស្សនោះច្បាស់ គឺគ្មាននរណាក្រៅពីមិត្តចន្ទ ដែលធ្លា
ជាប់គុកជាមួយនឹងខ្ញុំនៅលើកោះត្រឡាចរាប់ឆ្នាំ ។

ឯចន្ទក៏មើលឃើញខ្ញុំច្បាស់ដែរ គេឲ្យមាក់ដៃបញ្ឈប់សកម្មភ
ហើយខមានដោយរន្ធត់ និង រំភើប ៖

- ត្តា ! . ប្អូនទេ ! . ( សំឡេងរបស់គេហត់គឃ្លរ )
- ខ្ញុំហ្នឹងហើយ ចន្ទឯងមានរឿងអីហ្នឹង ? . . ( ខ្ញុំឆ្លើយនិងស
វិញដោយខ្ទាន់ )
- ជួយរកកន្លែងឲ្យខ្ញុំពួនផង ពួកទាហានកំពុងដេញតាមចាប់ខ្ញុំ !
- យី ! វីរហើយ ! . .



មកដល់ពេលនេះ ខ្ញុំក៏តក់ស្លុតណាស់ដែរ ប៉ុន្តែពេលនោះមាន
ហានម្នាក់រត់ឡើងមកដល់ទីតាយធំ ហើយវាសស្រែកកំហែងឡូឡាតាម
មើលចន្ទ ។ ឃើញដូច្នោះ មិនបង្អង់ឲ្យខាតពេលវេលាទាន់ ខ្ញុំក៏ចាប់
មិត្តកំសត់រត់ទៅខាងមុខព្រះវិហារ ហើយចុះតាមជណ្តើរធំភ្លាម ។
ណាលគ្នានោះ ឮសូរសំឡេងទាហានបារាំងនៅឡើង និង ទាហានខ្មែរ
ក់ស្រែកប្រាប់ថា " វាត់ចុះទៅវិញហើយ " ។

ក្នុងស្ថានភាពគ្រោះថ្នាក់បែបនេះ បើញញារតែមួយវិនាទីក៏អាចធ្វើឲ្យ
នគ្រោះថ្នាក់ដល់ជីវិតដែរ ។ ជាមួយនឹងសន្ធឹករជើងមនុស្សរត់ដេញ
ត្រីកគគ្រេងនោះ មានឮសូរបាញ់កាំភ្លើងមួយគ្រាប់ផង ប៉ុន្តែគ្រាប់សំ_
វាបានហើរព្រួលខ្យល់ពីលើក្បាលយើងយ៉ាងខ្ពស់ ព្រោះយើងបានចុះ
កដល់ចង្កេះភ្នំជាស្រេច ។ ចុះផុតពីភ្នំ ខ្ញុំរត់គ្របាញ់ជើងទៅទិសខាង
កើត ហើយគេចចូលទៅក្នុងព្រៃចង្អៀត តាមចន្លោះផ្ទះរបស់គេ ឯមិត្ត
ខ្ញុំក៏រត់ប្រកិតតាមពីក្រោយខ្ញុំទៅដែរ ។

សំឡេងរបស់ពួកទាហានបារាំង ឮស្រវែតនៅតាមផ្លូវធំប៉ុណ្ណោះ ។
យសន្ទុះ យើងទាំងពីរនាក់ក៏មកដល់កំពង់ផែដូចបំណងរបស់ខ្ញុំ ។ ជា
សំណាងល្អ ដោយមេឃងងិតភ្លៀង អ្នកលក់នំចំណីនៅមាត់ទន្លេដែលធ្លាប់
តែអុជចង្កៀងភ្លឺព្រោងព្រាតរាល់យប់នោះ ពេលនេះពើរីរាំងឈប់លក់គ្មាន
សល់ម្នាក់សោះ ធ្វើឲ្យទីនោះងងឹតខុសពីធម្មតា ។

ពេលទាល់ច្រករបៀបនេះ ខ្ញុំគិតថា មានតែត្រូសារត្រីរសទេ ដែល
អាចជួយខ្ញុំបាន ។ ខ្ញុំទាញដៃចន្ទឲ្យក្រាបជាមួយគ្នាពួនពីក្រោយគំនរបាច់

អំពោធាប់នឹងមាត់ច្រាំង ដើម្បីស្ដាប់ស្ទង់ស្ថានការណ៍សិន ។ ពុ
ឃើញមានអ្នកណាភ្ញាក់ផ្អើល ខ្ញុំក៏ដឹកដៃច័ន្ទចុះទៅលើផែ ហើយខ្លួន
ក្ដារស្ពានសំដៅទៅទូកពុរីសក្ហាម ព្រោះខ្ញុំដឹងថា យប់នេះទូករបស់
នៅចតឯក្ដីពេញ ស្អែកទើបត្រឡប់ទៅផ្ទះវិញ ។ ទូករបស់ពុរីសចិ
កន្ទេងល្អណាស់ ហើយខ្ញុំធ្លាប់ចេញចូលព្រឹកល្ងាចផង ផ្ទុះគ្មានរ
ច្រឡំស្ពានអាចកើតឡើងទាល់តែសោះ ។

គ្រាន់តែបានដល់ទូកក្ហាម ខ្ញុំទាញដៃច័ន្ទស្ទុះចូលទៅល្វែងខាង
យាក់បីស្ទួចជាផ្ទះរបស់ខ្លួនអីចឹង ។ មាលា កំពុងតែអង្គុយផ្ញសផុល
ក្រោយពន្លឺចង្កៀង ឃើញមុខខ្ញុំ មុនដំបូងនាងភិតភ័យ ប៉ុន្តែលុះសំគា
ឃើញអាកប្បកិរិយាស្លូតស្លោចខ្មែររបស់ខ្ញុំ នាងក៏ទម្លាក់ឈ្នុលចោ
ហើយរត់តាមសួរ ៖

- បងប្អូនមានរឿងអី ?

- ពួកទាហានគេកំពុងដេញតាមចាប់ខ្ញុំ និងមិត្តម្នាក់នេះ ( ខ្ញុំឆ្លើ
ទាំងហត់ស្ទើរដកដង្ហើមមិនដល់គ្នា )

- យ៉ស ! ស្លាប់ហើយ ( នាងឧទានទាំងរន្ធត់ )

ដោយសារនៅពីក្រោយដំបូលងងឹតពេក ខ្ញុំពុំអាចមើលឃើញទឹ
មុខគក់ស្លុតរបស់នាងទេ ប៉ុន្តែខ្ញុំកាត់យល់ថា មាលាកំពុងមានការព្រួ
បារម្ភខ្លាំងណាស់. . . បន្ទាប់មក ស្រាប់តែឮសំឡេងពួកទាហាន និងពួ
បារាំងនិយាយគ្នា រ៉ូសរ៉ាសនៅលើមាត់ច្រាំង បញ្ជាក់ឲ្យដឹងថា ពួក
ដេញតាមមកដល់ទីនោះហើយ ។ វីមីងហែប ដែលកំពុងសម្រាក



ល្វែងខាងក្រោយកៀនជញ្ជាំងម្ខាងនោះ ក៏ភ្ញាក់ស្ទុះស្រើងបម្រើង ។ លុះ
ឃើញខ្ញុំ និងច័ន្ទ គាត់ក៏ស្រែកសួរ ៖

- មានរឿងស្អីកូយ ? . . .

មាលាខ្សឹបកាត់ ៖

- ម៉ែកុំមានប្រសាសន៍ឮពេក ! . . .

ពោលផុតពីមាត់ មាលាស្ទុះទៅបើកគំរបឃ្នុបទូក ហើយពោលមក
កាន់ខ្ញុំ ៖

- បងប្អូន នាំគ្នាចុះទៅ ! . . .

ខ្ញុំចង់ពោលសរសើរប្រាជ្ញាវាងវៃរបស់មាលា ប៉ុន្តែគ្មានពេលវេលា
គិតច្រើនឡើយ ខ្ញុំរុញមិត្តច័ន្ទឲ្យចុះទៅមុន ទើបខ្ញុំចុះតាមក្រោយ បន្ទាប់
មកមាលាក៏បិទគំរបវិញភ្លាមដែរ . . .

គ្រាន់តែចូលពួនផុតបន្តិច សំឡេងច្រួលច្របល់របស់មនុស្សនៅក្នុង
ទូកនាវា នៅជុំវិញទីនោះក៏លាន់ឡើងអឺអរមួយរំពេច ព្រោះពួកទាហាន
បារាំងបានមកដល់លើផែហើយ ។ ខ្ញុំមើលមិនឃើញសកម្មភាពរបស់
ពួកវាទេ ប៉ុន្តែសំឡេងទាហានម្នាក់ស្រែកសួរ ៖

- មានអ្នកណាឃើញមនុស្សប្រុសពីរនាក់ចូលទៅក្នុងទូកទេ ? .

ឮសំនួរនេះ សំឡេងអឺអរភ្ញាក់ផ្អើលទាំងប៉ុន្មានក៏បាត់ស្ងាត់អស់ទៅ
វិញ ហើយគ្មានសំឡេងឆ្លើយតបសោះ ។ មួយសន្ទុះឮសំឡេងទាហាន
ដដែលស្រែកដោយយ៉ាងក្ដៅក្រហាយ ៖

- ពួកអ្នកទូកអស់ហ្នឹងសុទ្ធតែថ្លង់ទេឬ ? . . . បើថ្លង់ចាំខ្ញុំចុះទៅ

ទោះបន្ទុះក្រដាសត្រចៀកឡ !..

បន្ទាប់ពីពាក្យគំរាមកំហែងនេះ មានសំឡេងបុរសម្នាក់និយាយភាសាខ្មែរបំបែរ ។ ដែលមានសំនៀងជាជនជាតិចាមឆ្លើយតបវិញ ៖

- ជំរាបប្រសាសន៍សេប ទូករបស់ខ្ញុំគ្មានមនុស្សចម្លែកឡើងមកទេបាទ !..

ខណៈនោះ ឮសំឡេងទាហានបារាំង ស្រែកគ្រហឹមឡូឡាអូចយក្ស ។ តមកទៀត ឮសំឡេងទាហានខ្មែរដែលនោះស្រែកប្រាប់គ្នីគ្នា ៖

- លោកអាស្ពឺដង់ បញ្ជាឲ្យឆែកមើលទូកទាំងអស់កុំឲ្យសល់មួយឲ្យសោះ ព្រោះតាមអ្នកលក់ច្រេងស៊ីគ្គ * ប្រាប់យើងនៅខាងលើអម្បាញ់មិញថា ឃើញមនុស្សពីរនាក់រត់ចុះមកច្បាស់ណាស់ ។

ឮដូច្នោះ ខ្ញុំប្រហោងពោះឆ្ងល់តក់ស្លុតម្ដងទៀត ប៉ុន្តែមិត្តចំនួនឲ្យបដាក់ត្រចៀកខ្ញុំ :

- ទូកច្រើនម៉្លឹងៗ តើវាឆែកអស់ដែរ ? .. ទោះបីឆែកអស់ ក៏ត្រូវចំណាយពេលយូរដែរ ព្រោះពួកវាមានគ្នាតែប្រាំបួននាក់ទេ ដូច្នេះយើងអាចប្ដូរកន្លែងគៀសខ្លួនចេញពីទូកនេះបាន ។

- ទោះបីយ៉ាងណា ក៏ត្រូវសួរយោបល់មាណាសិនដែរ ( ខ្ញុំឆ្លើយ )

- គឺនាងអម្បាញ់មិញហ្នឹងអ្ហី ? ..

---

* ច្រេងម៉្សាង ច្រើសំរាប់ចាក់ចង្កៀងភ្លើងប្រយោននៅពេលយប់ នៅសម័យនោះភ្លើងប្រយោនដែលគេយកប្រេងមកចង្កៀងចំភ្លើ ។



- ត្រូវហើយ !..

បន្ទាប់មក ខ្ញុំនិងចំនួនក៏នៅស្ងៀមស្ងាត់ទាំងអស់គ្នា ព្រោះឮសូរសន្ធឹកជើងម្នាក់យ៉ាងខ្លាំងនៅខាងក្រៅ ។ ហើយនៅពីលើក្បាលយើងក្នុងទូកឮសូរសំឡេងគ្រីសកំពុងជជីកសួរកូនស្រី ។ បើតាមស្មានប្រហែលជាគាត់មានការឆ្ងល់នៅទូកអ្នកជិតខាង លុះមានការឆែកឆេរឆ្អើលនោះឡា ទើបត្រឡប់មកទូកវិញ ។

ដោយហេតុលើសំឡេងញ័រភ្លៀង គ្រីសនិយាយពេញសំឡេងអត់ខ្លាចឮដល់ពួកបារាំងទេ ធ្វើឲ្យខ្ញុំស្ដាប់ឮច្បាស់គតចន្លោះ ។ ពាក្យដំបូងរបស់គាត់និយាយដោយសំឡេងញ័រៗ ក្នុងសភាពព្រួយបារម្ភ :

- ចូជាន់វាមកពីណា ហើយមានរឿងអី ? ..

- ខ្ញុំអត់បានសួរទេ ព្រោះកំពុងអង្គុយផ្លុំសមង ស្រាប់តែឃើញពួកគាត់ទាំងពីរនាក់រត់ចូលមក ហើយពួកទាហានក៏ដេញតាមមកដល់មាត់ច្រាំងដែរ ។

- ម្នាក់ទៀតជាអ្នកណា ? .. ( គ្រីសសួរសង្ខេញ )

- ខ្ញុំអត់ដែលស្គាល់សោះពុក មិនដែលជាកម្មករលីសែងនៅកំពង់ផែជាមួយនឹងគាត់ទេ !..

ស្ងប់ស្ងាត់បន្តិច ទើបឮម៉ីឆហៃបញ្ចេញយោបល់ ៖

- ខ្ញុំដូចជាពុំជឿថា ក្មួយចូជាន់ជាមនុស្សទុច្ចរិតសោះឡូយក៏...

គាត់និយាយដល់ត្រង់នេះ ក៏បាត់មាត់ឈឹងទៅវិញ ហាក់ដូចជាភ័យខ្លាចពីរឿងអ្វីមួយ ។ ប៉ុន្តែខ្ញុំគាត់យល់គេកទៅហើយ ថាប្អាយ

របស់មាណវិកាមរៃថា ខ្ញុំប្រហែលជាទាក់ទាមដល់រឿងនយោបាយទៀតហើយ ។

ពេលនោះសន្ធឹកភ្លៀងកាន់តែខ្លាំង ហើយទូកទាំងមូលឃ្លេងឃ្លោងឥតឈប់ឈរ បញ្ជាក់ឲ្យដឹងថាខ្យល់ក៏បក់បោកខ្លាំងណាស់ដែរ ។ សំឡេងពួកទាហានចោរវៀងស្អប់ស្អាត់របស់យើង សំឡេងពួកម្ចាស់ទូកនានាក៏ស្ងាប់លែងឮដែរ ។

សំងំអស់រយៈពេលមួយសន្ទុះធំ ទើបចិន្តខាប់ដៃខ្ញុំច្របាច់យ៉ាងតឹង ហើយពោលដោយមនោសញ្ចេតនារំភើបញាប់ញ័រ :

- ខ្ញុំពុំគួរធ្វើឲ្យបងជាប់មានទុក្ខទោសដោយសារខ្ញុំយ៉ាងនេះទេ ព្រោះបងទើបនឹងរួចពីគុកប៉ុន្មានខែសោះ ។ បើកុំតែបានឯងនាំមកទីនេះ ម្ល៉េះសមខ្ញុំត្រូវពួកទាហានចាប់បានទៅហើយ . . . ខ្ញុំអង្អែលស្មាមិត្តចិន្តកំសត់ :

- យើងធ្លាប់រងទុក្ខទោសជាមួយគ្នានៅលើកោះត្រឡាចរាប់ឆ្នាំមកហើយ ថ្វីបើយើងមានសញ្ជាតិផ្សេងគ្នាមែន ប៉ុន្តែខ្ញុំចាត់ទុកចិន្តដូចជាបងប្អូនបង្កើតអ៊ីចឹង ប៉ុន្តែយើងឥឡូវពុំទាន់ប្រាកដជារួចផុតពីគ្រោះថ្នាក់ដែរ ។

- ទោះបីយ៉ាងណាក៏ប្អូនជាឯងជាអ្នកមានគុណលើខ្ញុំធ្ងន់ណាស់

- គ្មានជាគុណស្រីយអីទេចិន្ត យើងសុទ្ធតែជាអ្នកបដិវត្ត ធ្វើការតស៊ូរំដោះប្រទេសជាតិ ចេញពីនឹមត្រួតត្រារបស់អាណានិគមនិយមបារាំងដូចគ្នា ដូច្នេះពេលមានអាសន្ន យើងត្រូវតែសាមគ្គីជួយគ្នាទៅវិញ



ទៅមកអ៊ីចឹងហើយ . . .

ក្នុងពេលយប់មានភ្លៀងព្យុះ ហើយស្ថិតនៅក្នុងបាតទូកងងឹតចាក់ភ្នែកពុំយល់យ៉ាងនេះ យើងពុំអាចមើលមុខគ្នាឃើញទេ ប៉ុន្តែស្រាប់តែមានតំណក់ទឹកក្តៅឧណ្ហ ៗ ស្រក់មកលើដៃខ្ញុំពីរបីតំណក់ ធ្វើឲ្យខ្ញុំស្រួលដើមក និយាយលែងចេញ ព្រោះខ្ញុំដឹងថា មិត្តចិន្តស្រក់ទឹកភ្នែក គឺមិត្តរបស់ខ្ញុំយំដោយក្តីរំភើបហួសប្រមាណ មិនមែនយំដោយសាររឿងកំសត់ទេ !. . .

ទូកនៅតែឃ្លេងឃ្លោង និងរលេះឥតឈប់ឈរ ។ មួយសន្ទុះធំ ទើបចិន្តសួរដោយសំឡេងញ័រ ៗ ហាក់ទើបផុតពីការខ្សឹកខ្សួល :

— ឯងត្រូវគេដោះលែងយូរខែមកហើយ ហេតុអីបានជាឯងពុំទាន់ត្រឡប់ទៅប្រទេសឡាវវិញ ?

ខ្ញុំឆ្លើយ ដោយមិនបាច់គិត :

- មកពីខ្ញុំអត់សោហ៊ុយ និយាយលាក់បាំងអី សព្វថ្ងៃខ្ញុំសំឲ្យព្រាត់គាសបានខ្លះហើយ ប៉ុន្តែដូចជាចង់រស់នៅស្រុកខ្មែរឲ្យបានយូរបន្តិច ?.

- ឯងរកស៊ីអី ?. .

- គ្មានរកស៊ីអីលែងនៅតែកំពង់ផែហ្នឹង !. . អូ !. . ខ្ញុំពុំទាន់សួរឯងផង ចិន្តឯងលួចចេញពីគុកឬ បានជាគេដេញចាប់ !. .

- មិនមែនអ៊ីចឹងទេ ! បន្ទាប់ពីគេដោះលែងបានប្អូនដប់ថ្ងៃ គេក៏ហៅគ្នាទៅកាត់ទោសសាជាថ្មី ហើយដោះលែងដែរ ព្រោះពួកយើងនៅក្មេង ៗ ហើយណាមួយគុកក៏កាន់តែចង្អៀត . . .

- ចុះឯងមានរឿងអីទៀត ?..

ស្ងៀមបន្តិច ចិន្តារៀបរាប់ប្រាប់ ៖

- បន្ទាប់ពីរួចពីគុក គ្នាត្រឡប់ទៅខេត្តកំពង់ឆ្នាំង ដែលជាស្រុកកំណើតវិញ ហើយបន្តការតស៊ូក្នុងចលនាឥស្សរៈតទៅទៀត !..

- ល្អ ! គំនិតរបស់ឯងពេញចិត្តខ្ញុំណាស់ ! យើងកុំត្រូវចុះចាញ់ពួកអាណានិគមនិយមបារាំងឲ្យវាកាន់កាប់ទឹកដីជិះជាន់ប្រទេសជាតិយើងតទៅទៀតទេ ...

ចិន្តាសប្បាយចិត្ត ហើយរៀបរាប់ពីរឿងមួយយ៉ាងសំខាន់ប្រាប់ខ្ញុំ :

- បងផាត់ដឹងទេ ឥឡូវនេះបក្សកុម្មុយនីស្តឥណ្ឌូចិនយើង បានបំបែកចេញជាបក្សពលករវៀតណាម បក្សប្រជាជនបដិវត្តខ្មែរ បក្សប្រជាជនបដិវត្តឡាវ ហើយបក្សនីមួយៗ បានម្ចាស់ការដឹកនាំបំផុសប្រជាជនធ្វើការតស៊ូរំដោះប្រទេសជាតិរៀងខ្លួន ប៉ុន្តែយើងនៅតែសាមគ្គីជួយគ្នាទៅវិញទៅមកដដែល !..

- មានរឿងអីចឹងផង ! ប្រសើរណាស់ នេះមកពីចលនាបដិវត្តរបស់ប្រទេសទាំងបីនៅឥណ្ឌូចិនយើងរីកចំរើនធំធាត់មែនទេ ?..

- ត្រូវហើយបងផាត់ !..

- ចុះហេតុអីបានជាឯងត្រូវពួកទាហានដេញចាប់ ?..

- ខ្ញុំបានត្រូវអង្គការចាត់តាំងឲ្យមកទិញថ្នាំពេទ្យ និង យកទាក់ទង និង ខ្សែរយៈរបស់ចលនាឥស្សរៈនៅភ្នំពេញ ប៉ុន្តែត្រូវពួកបារាំងស៊ើបដឹង ទើបវាទៅពួនចាប់ខ្ញុំនៅម្តុំស្ពានតូចនោះ !..



គ្នាដឹងខ្លួនទាន់ពេលវេលា ក៏ចុះទៅបង្កប់នៅក្នុងទឹកបឹងដែលមានកំពោកច្រើនរាប់រយ៉ាង ទើបឡើងមកត្រើយខាង ប៉ុន្តែត្រូវពួកទាហានឃើញពីចំងាយ ពួកវាក៏នាំគ្នាដេញចាប់រហូតមកដល់វត្តនេះ ហើយបានជួបនឹងបងផាត់ឯងជួយនឹងស្រាប់ !..

ខ្ញុំបន្ទរស្តីឆ្លើយគាត់ ៖

- ហ៊ឺ !.. អញ្ចឹងមិញនេះ ឯងរ៉ៃតែនឹងបានទៅជាប់ខ្នោះនៅលើកោះត្រឡាចជាលើកទីពីរទៀត !..

- ត្រូវហើយបងផាត់ ប៉ុន្តែមុខបញ្ជូនទៅកោះ ច្បាស់ជាត្រូវត្រៅត្រាស្ទើរស្លាប់ ស្ទើររស់ជាមិនខានទេ !... តើឥឡូវនេះគិតយ៉ាងម៉េចទៅ ឬមួយក៏ខ្ញុំត្រូវចេញទៅបង្ហាញខ្លួន ដើម្បីកុំឲ្យជាប់ពិរុទ្ធដល់ឯង និងដំពាក់ដំពិនដល់ម្ចាស់ទូក !..

- គ្មានរឿងបែបនេះទេ ទោះបីត្រូវស្លាប់ក៏ខ្ញុំសុខចិត្តស្លាប់ជាមួយចិន្តាឯងដែរ ពេលកំពុងតែមានភ្លៀងព្យុះអីចឹង បើយើងចេញពីទូក ហើយចុះទៅក្នុងទឹកបោលកៀសខ្លួន ប្រហែលជាអាចគេចផុតពីភ្នែកពួកវាបាន

ចិន្តាចាប់បាតដៃខ្ញុំច្របាច់មួយទៀត ពោលដោយអំណរ ៖

- មធ្យោបាយនេះប្រសើរណាស់ ! ប៉ុន្តែម្ចាស់ទូកផ្ទះនេះ ត្រូវយ៉ាងម៉េចនឹងបងផាត់ឯង ?..

- ទើបនឹងស្គាល់គ្នាប្រហែលបួនប្រាំខែចុះណ្ណោះ !.. គាត់ជាមនុស្សមានចិត្តសប្បុរស ហើយគាត់ស្រឡាញ់រាប់អានខ្ញុំណាស់ !..

ខណៈនោះ ស្រាប់តែឃ្លុបទូក ត្រូវគេបើកឡើង ហើយពន្លឺភ្លើង

ចង្កៀងគោម ក៏ឆេះចូលដល់បាតទូក ធ្វើឲ្យខ្ញុំព្រលឹងនៅចុងសក់ ព្រោះយល់ថាពួកចោរហានជាវាបានដេញតាមមកដល់ទូកនេះហើយ . . . ច័ន្ទស្ទុះទៅម្ខាងគេចពីពន្លឺភ្លើង ប៉ុន្តែឮសំឡេងម្ចាស់ទូកស្រែកហៅ ÷

- ក្មួយបុផាន់ចេញមក ! . .

ដោយខ្ញុំនៅអែះអុញពុំក្រោកឡើងទៅលើ មាលាស្រែកប្រាប់ ÷

- ឡើងមកបងបុផាន់ យើងផុតពីគ្រោះថ្នាក់ហើយ . . .

និមិត្តតែឮពាក្យនេះ ខ្ញុំអរកើត ហើយងើបឈរត្រង់ខ្លួន ក្រត់ដៃលើក្ដារទូកយោងខ្លួនផាត់ចេញមកខាងលើភ្លាម . . . ឃើញពូរ៉ុសឈរកាន់ចង្កៀងគោមបំភ្លឺជំទាវដោយទឹកមុខស្ងប់ស្ងៀម . . .ឯម៉ឺនហែមនិងមាលាកំពុងចែវទូក ម្នាក់នៅខាងក្បាល ម្នាក់នៅខាងកន្សៃ . . . ពេលនេះទើបខ្ញុំដឹងថា ទូកកំពុងស្ថិតនៅកណ្ដាលទន្លេ ឆ្ងាយពីកំពង់ដែណាស់ហើយ . . សេចក្ដីភ័យខ្លួនរលាយបាត់អស់មួយរំពេច ខ្ញុំស្រែកហៅមិត្តកំសត់ ÷

- ច័ន្ទអើយឡើងមក ! . .

ច័ន្ទក៏ងាកចេញពីបាតទូកភ្លាម លុះប្រទះឃើញពូរ៉ុសក៏ផ្គងដៃសំពះ ÷

- ជំរាបសួរលោកពូ ! . .

ពូរ៉ុសងក់ក្បាលឆ្លើយតបសមតាមសភាពគាត់ជាមនុស្សចាស់ទុំ . . ដំណាលគ្នានោះ ម៉ឺនហែមក៏បន្លឺមកពីខាងក្រោយ :

- ក្មួយទាំងពីរសំណាងធំណាស់ ! . .

ឮដូច្នេះ មាលាដែលកំពុងតែចែវទូកហាលភ្លៀង ក៏ទៅភ្ញៀត



សំដែងសេចក្ដីគោរពដោយស្រែកមកកាន់ខ្ញុំ :

- បងបុផាន់ តែប៉ុណ្ណេះ បងរួចខ្លួនហើយ . . .

ខ្ញុំសម្លឹងមុខពូរ៉ុស សំដែងសេចក្ដីដឹងគុណ :

- លោកពូចេញទូកពីដែមត ពួកវាអត់ឃាត់ទេ ? . .

ម្ចាស់ទូកពោលដោយទឹកមុខនឹងធ្ងន់ដដែល

- ធ្វើម៉េចនឹងដឹង បើភ្លៀងធ្លាក់ខ្មៅងងឹតដី ហើយពួកវារវល់តែនាំគ្នាទៅស៊ីផ្លែកក្នុងកច្ចាល់ដែលប្រុងធ្វើដំណើរទៅក្រចេះនោះ ណាមួយទូកក៏មានច្រើនកកកុញផង ពួលចេញសន្សឹមមកវាមើលមិនឃើញទេ!

មកដល់ពេលនេះ ទើបខ្ញុំឃើញទូកនេះតែម្ដងយោលនិងអង្រួះឡើង ! . . ខ្ញុំកើតហើយដឹងគុណគ្រួសារពូរ៉ុសលើសពេលណាទាំងអស់ ហើយស្ទុះចេញទៅខាងកន្សៃ :

- មាលាហត់ណាស់ ទុកឲ្យខ្ញុំចែវម្ដងវិញ ! . . .

- ទេបងជ្រកនៅខាងក្នុងចុះ ព្រោះជិតដល់ផ្ទះហើយ . .

ខ្ញុំពុំសុខចិត្តក៏ដណ្ដើមចែវពីដៃមាលាទាល់តែបាន ប៉ុន្តែលុះចែវបានពីរបីផុត ស្រាប់តែទូករេក្បាលរកកសមកក្រោយវិញ . . . ឃើញដូច្នោះ មាលាគាច់កសើចកក្អិក ហើយចាប់ចែវពីដៃខ្ញុំយកទៅវិញ . . . តាមការពិតខ្ញុំអត់ចេះចែវទូកទេ ប៉ុន្តែដោយមានភាគខាងពេក ទើបដណ្ដើមពីនាង ! . .

មាលាយល់ចំណុចនេះដែរ ទើបនាងសើច ហើយនាំនិយាយបន្ទុំការគៀនខ្មាសរបស់ខ្ញុំ :

- មិនអីទេ ចាំថ្ងៃណាមួយ ខ្ញុំបង្រៀនបងបូជាន់ឲ្យចេះថែមទៀត .

នៅក្នុងទូកឯណោះវិញ ពូរីសនិងច័ន្ទអង្គុយជក់បារីទល់មុខគ្នា ។ ច័ន្ទបានរៀបរាប់អំពីហេតុការណ៍ ដែលគេបានប្រព្រឹត្តកន្លងមកប្រាប់ម្ចាស់ទូកតាមត្រង់ទាំងអស់ . .

ខ្ញុំគិតបន្តិចក្នុងពោះថា ពូរីសច្បាស់ជាខឹងសំបារនឹងខ្ញុំ ដែលនាំអ្នកជាប់គុកម្នាក់មកក្រុកខ្លួនក្នុងទូកនាំពិបាកដល់គាត់ហើយ ដឹងអីផ្ទុយស្រឡះទៅវិញ បន្ទាប់ពីបានស្តាប់ការរៀបរាប់របស់ច័ន្ទសព្វគ្រប់ហើយ ស្រាប់តែគាត់ញញឹមញញែមសំដែងការពេញចិត្តយ៉ាងខ្លាំង ខុសពីកាលទើបជួបមុខដំបូង ! . . ទីបំផុតគាត់បានពោលយ៉ាងខ្លីប្រាប់ច័ន្ទ :

- ក្មួយកុំព្រួយបារម្ភអី ជាភ័ព្វសំណាងរបស់ក្មួយទេ ដែលបានមកជួបនឹងពូ ព្រោះពូក៏ជាអ្នកបំរើក្នុងចលនាតស៊ូឥស្សរៈម្នាក់ដែរ ប៉ុន្តែការតស៊ូរបស់ពូខុសផ្សេងពីក្មួយ ! . .

ឮដូច្នោះ ខ្ញុំមានការគក់ក្តៅជាខ្លាំង ហើយភ្ញាក់ផ្អើលតែក្នុងចិត្ត ព្រោះតាំងពីដើមមក ខ្ញុំពុំដែលនឹកស្មានទាល់តែសោះថា ពូរីសជាខ្សែរយៈរបស់ចលនាឥស្សរៈ ដូច្នេះគាត់ជាមនុស្សម្នាក់ដែលពូកែលាក់អាថ៌កំបាំងជាទីបំផុត ។

យប់យន់បន្តិចទៅហើយ ភ្លៀងក៏រាំងដាច់គ្រាប់ល្មម មេឃស្រឡះផ្កាយរះព្រោងព្រាត . . . ខណៈនោះ មាលាវារទូកចូលចតទៅនឹងស្ពានឈើមួយ ហើយពោលមកកាន់ខ្ញុំ :

- យប់នេះ បងបានស្គាល់ផ្ទះខ្ញុំហើយ !



ខ្ញុំឆ្លៀតនិយាយលេង :

- បើកុំតែមានរឿងបែបនេះកើតឡើង ប្រហែលខ្ញុំគ្មានវាសនាស្គាល់ផ្ទះរបស់មាលាទេ ! . .

- ស្អប់បងបូជាន់ណាស់ ! . . . ( នាងសម្លក់ទាំងញញឹមពព្រាយ

ពូរីសនាំខ្ញុំនិងច័ន្ទឡើងទៅលើផ្ទះគាត់ដែលនៅប្រឈមនឹងមាត់ទន្លេ ! គឺជាគេហដ្ឋានមួយធំទូលាយសង់អំពីឈើ ប្រក់ក្បឿងមានបង្អួច និងរបងព័ទ្ធជុំវិញយ៉ាងស្អាតបាតសមរម្យ . . .

ឡើងដល់លើផ្ទះបន្តិច ពូរីសយកខោអាវជិតរបស់គាត់មួយសំរាប់និងក្រមាមួយមកហុចឲ្យច័ន្ទ :

- ផ្លាស់ខោអាវសិនទៅក្មួយ ( ព្រោះខោអាវច័ន្ទនៅសើម )

ខណៈនោះ មាលាក៏ចូលទៅចង្ក្រានបាយ បង្កាត់ភ្លើងដណ្តាំស្លទាំងយប់ ធ្វើឲ្យខ្ញុំកាន់តែពិបាកចិត្តចំពោះសប្បុរសធម៌ហួសហេតុរបស់គ្រួសារពូរីសមកលើរូបខ្ញុំ ហើយមិនដឹងថាខ្ញុំត្រូវសងគុណវិញដោយវិធីណា . . .

ប្អូនប្រុសរបស់មាលា អាយុប្រហែល ១០ ឆ្នាំ វាភ្ញាក់បើកទ្វារចូលជួបពុកម្តាយនិងបងស្រី លុះឃើញខ្ញុំនិងច័ន្ទដែលជាមនុស្សចម្លែក វាដើរមកមើលមុខ ទើបរត់ទៅសួរមីងហែម :

- អ្នកណាគេហ្នឹងម៉ែ ? . . .

មីងហែមរុញខ្លួនកូន :

– បងប្អូនយើងមកពីស្រុកណា កូនឯងទៅដេកវិញទៅ ព្រឹកគង់តែស្គាល់ទេ ! . .

កំពុងតែសើចយ៉ាងស្រាប់ផង កូនប្រុសរបស់ពូរ៉ុសក៏ដើរទៅប្រះខ្លួនលើគ្រែរៀងវិញភ្លាម ។

ក្រោយពីបាយទឹករួចហើយ ខ្ញុំនិងច័ន្ទសម្រាកនៅល្វែងខាងមុខ ។ ប៉ុន្តែយើងទាំងពីរនាក់ដេកឥតលក់សោះ ហើយនាំគ្នាខ្សឹបខ្សៀវសំណេះសំណាលរៀបរាប់ពីការរស់នៅក្រោយពេលបែកគ្នាពីកោះត្រឡាច ប្រាប់គ្នាទៅវិញទៅមក ។ ឆ្លងកាត់គ្រោះថ្នាក់ក្នុងរាត្រីនេះ យើងរឹតតែស្រឡាញ់គ្នាលើសពីកាល ដែលរស់នៅលើកោះត្រឡាចរាប់ឆ្នាំនោះទៅទៀត ។

មាន់រងាវទៀបភ្លឺ ច័ន្ទក្រោករៀបចំខ្លួន ហើយសំពះលាព្រមទាំងថ្លែងអំណរគុណចំពោះពូរ៉ុសនិងមីងហៃមសារជាថ្មីម្តងទៀត ។ ម្ចាស់ផ្ទះទាំងពីរនាក់ប្តីប្រពន្ធក៏ជូនពរសព្ទសាធុការដល់ច័ន្ទដែរ ។

ខ្ញុំជូនដំណើរមិត្តចេញផុតពីភូមិ ច័ន្ទងាកមកចាប់ស្មាខ្ញុំអង្រួនសើរទាំងទឹកមុខអាឡោះអាល័យ :

- អរគុណហើយសំឡាញ់ !

មេឃនៅទិសខាងកើតពណ៌ក្រហមច្រៀងៗហើយ ធ្វើឱ្យខ្ញុំអាចមើលមុខច័ន្ទច្បាស់ជាងមុន គេមានសាច់ឈាមធំធាត់ខុសកាលពីពេលជាប់គុកនៅលើកោះត្រឡាចឆ្ងាយណាស់ !

ថ្វីបើធ្លាប់ស្គាល់គ្នារាប់ឆ្នាំមកហើយ ប៉ុន្តែពេលនេះ ខ្ញុំទើបពិនិត្យ



ចំណាំពិនភាគតិច ហាក់ដូចមនុស្សទើបនឹងស្គាល់គ្នាជាលើកដំបូង ។ ច័ន្ទមានមាឌខ្ពស់ស្រឡះ ដំណើរដ៏រឹងបញ្ជាក់នូវចរិតមិនខ្ជិល សម្បុរសណ្តែកបាយ សក់រួញអង្កាញ់ បង្ហាញនូវចរិតស្មោះត្រង់ ចិញ្ចើមដិតក្រាស់ បបូរមាត់បង្ហាញនូវចរិតក្លាហាន និង ជាមនុស្សមានប្រាជ្ញាវាងវៃ ។

ឃើញខ្ញុំសម្លឹងមុខគេមិនដាក់ភ្នែក ច័ន្ទបន្តសំដីទៀត ៖

– កុំពិបាកចិត្តអីបន្តិច ! ខ្ញុំជឿជាក់ថា នៅថ្ងៃអនាគតកម្លាំងបដិវត្តរបស់ប្រជាជនប្រទេសទាំងបីនៅឥណ្ឌូចិន ពិតជាឈ្នះលើពួកអាណានិគមនិយមបារាំងជាមិនខាន ដល់ពេលនោះ បើខ្ញុំមានភ័ព្វវាសនានៅគង់វង្សជីវិត ខ្ញុំនឹងទៅស្វែងរកមិត្តនៅឯប្រទេសឡាវទាល់តែឃើញ ព្រោះខ្ញុំស្គាល់ឈ្មោះស្រុកភូមិរបស់ឯងអស់ហើយ !. .

ខ្ញុំនឹកស្ងើចសរសើរចំពោះឆន្ទៈប្តូរផ្តាច់ក្នុងការតស៊ូរំដោះប្រទេសជាតិរបស់មិត្តច័ន្ទ ។ ខ្ញុំចាប់ឱបមិត្តក៏ស្រដីពោលទាំងក្តុកក្តួល ៖

- ឲ្យតែមានជីវិតនៅរស់ យើងទាំងពីរនាក់មុខជាជួបគ្នាឡើវិញ សូមមិត្តធ្វើដំណើរឲ្យបានសុខសប្បាយចុះណា ! . . .

ច័ន្ទសើចដាក់ខ្ញុំជាចុងក្រោយទាំងរលើងរលោងទឹកភ្នែក ទើបចាប់ដៃខ្ញុំលា ហើយត្រឡប់ខ្លួនដើរលឿនឡើង គេដើរឥតងាកក្រោយទាល់តែសោះ។ ខ្ញុំយល់ហើយ តាមការពិត ច័ន្ទមិនងាកក្រោយ ព្រោះគេពុំចង់ឲ្យការអាឡោះអាល័យនៅពេលបែកគ្នានេះ បង្អាយពេលវេលាយូរពេក ។

ខ្ញុំតាមមើលដំណើរមិត្តស្មោះខ្មែរ ទាល់តែបាត់ស្រមោលទៅនឹងចំការដំណាំនានា ទើបត្រឡប់ទៅវិញ ។

## ៥

## ស្នេហ៍

បន្ទាប់ពីមិត្តភក្តិបែកទៅ ខ្ញុំចេះតែសញ្ជឹងគិតម្នាក់ឯង ហើយការ តែចឹកអៀនខ្លួនឡើង ព្រោះតាំងពីស្គាល់គាត់មក ប្រមាណជាងកន្លះឆ្នាំ ហើយ គ្រួសារពូស្រស់ស្រឡាញ់រាប់អាន និងឧបត្ថម្ភខ្ញុំច្រើនណាស់ ។ ខ្ញុំជាមនុស្សអនាថា តែលតោលគ្មានទីពឹង ប្រកបរបរជាកម្មករលីសែង នៅកំពង់ផែអឹមចិន ពុំសមបើគាត់រាប់អានដល់ម្ល៉ឹងសោះ ។ ខ្ញុំពុំដែល បានធ្វើអំពើអ្វីជាកិច្ចតបស្នងសងគុណដល់គាត់នោះឡើយ ផ្ទុយទៅវិញ បែរជានាំរឿងអំពល់មកផ្តល់ឲ្យគាត់ថែមទៀត ។ កាលពីយប់មិញ បើពុំតែថៃជន្យល្អមានគ្រឿងធំអាចឲ្យលួចថយខ្លួនចេញបាន ម្ល៉េះសម ពូស្រស់ត្រូវជាប់ខ្នោះជាមួយខ្ញុំនិងមិត្តភក្តិស្រេចទៅហើយ ។

ដឹងពីសាកប្បកិរិយារបស់គាត់បែរជាផ្ទុយស្រឡះទៅវិញ នៅពេល ស្រស់ស្រូបអាហារពេលព្រឹករួចហើយ ពូស្រស់ទម្រេតខ្លួនក្នុងអង្រឹង បឹត ផារីស្លឹកសង្កែបង្ហុយផ្សែង ហើយស្រែកហៅខ្ញុំ ៖

- ឬជាន់មកណេះ ! . .

- បាទ ! លោកពូមានការអី ! ( ខ្ញុំឆ្លើយព្រមទាំងដើរទៅអង្គុយ (ក្បែរគាត់) គាត់សម្លឹងដំបូលផ្ទះ ហាក់សញ្ជឹងគិតបន្តិចទើបងាកមកសួរខ្ញុំ ៖



- សព្វថ្ងៃនេះ ក្មួយរស់នៅតាមសំយាបព្រះវិហារ គ្មានផ្ទះសំបែង អីចឹងពិបាកវេទនាណាស់មែនទេ ? . .

ខ្ញុំហាក់អេះអុញបន្តិច ទើបឆ្លើយតាមត្រង់ ៖

- លោកពូស្មានមិនខុសទេ លំបាកណាស់ ជួនកាលភ្លៀង ខ្យល់ ត្រូវគេមើលងាយមើលថោកណាស់ ។ ប៉ុន្តែក្មួយអើយ កម្មករ លីសែងទំនិញរស់ អ្នកណាក៏ដូចអ្នកណាដែរ លីសែងបម្រើព្រាស់អស់ កម្លាំងបាយ មួយថ្ងៃសម្រាប់ចិញ្ចឹមក្រពះតែមួយថ្ងៃប៉ុណ្ណោះ រកប្រាក់ទិញ សម្លៀកបំពាក់ស្លៀកពាក់ផង ដូច្នេះធ្វើមិនទាំងអាចជួលផ្ទះគេនៅ បាន ! . .

ខណៈនោះ មីងវ៉ែមដើរចេញមកពីក្នុងផ្ទះ ៖

- អើ . . . រឿងក្មួយមីងក៏ដឹងដែរ

ពូស្រស់គោះកញ្ចប់បារីចោល សម្លឹងមុខភរិយា ទើបពោលមក កាន់ខ្ញុំ ៖

- ពូបានពិគ្រោះគ្នារួចអស់ហើយ ពូមានកូនតែពីរនាក់ ។ ឯអា ហ៊ានវានៅក្មេងពេកណាស់ ហើយជាប់រៀនសូត្រ ពុំអាចជួយជំនួសដៃជើង ទេ ។ ពូឃើញឯងជាមនុស្សស្លូតត្រង់ស្មោះត្រង់គួររាប់អាន ឥឡូវនេះពូចង់ ឲ្យក្មួយឯងមកនៅជួយធ្វើការរកស៊ីជាមួយមីងពូ ទាំងគិតគូរឲ្យជាប្រាក់ខែ តែក្មួយថាម៉េចដែរ . . .

ខ្ញុំភ្ញាក់ភើតពោះ ព្រោះមិនទាន់ស្មានថា ខ្ញុំមានភ័ព្វវាសនាដល់ម្ល៉ឹង

សោះ ប៉ុន្តែមូលហេតុដែលនាំឲ្យខ្ញុំរំភើបកាន់តែខ្លាំងនោះ គឺខ្ញុំដឹងថា ពាក្យដែលពូរ៉ុសថាចង់ឲ្យខ្ញុំមកជួយរកស៊ីធ្វើការក្នុងគ្រួសាររបស់គាត់ គឺជាសំដីនិយាយលាក់លៀមមិនចង់ឲ្យខ្ញុំដឹងទឹកចិត្តគាត់ពេកទេ តាមការពិត គឺពូរ៉ុសគាត់ព្រួយបារម្ភ ខ្លាចខ្ញុំទៅដេកនៅទីងរត្តក្តី អាចជួបនឹងហេតុការណ៍អាក្រក់ដោយប្រការផ្សេង ៗ តទៅទៀត ! . . .

ខ្ញុំប្រញាប់ឆ្លើយពោលឧទានថា ៖

- បាទលោកគ្រូ អ្នកមីងអាណិតមេត្តាឲ្យរស់នៅជាមួយយ៉ាងនេះ គ្រេកអរណាស់ ឥតចង់បានប្រាក់ខែប្រាក់ថ្ងៃអីទេ សុំតែមួយពោះរស់មួយខ្លួនប៉ុណ្ណោះ ។ កិច្ចការធ្ងន់ស្រាលយ៉ាងណាក៏ដោយលោកគ្រូនិងអ្នកមីងប្រើខ្ញុំចុះ ហើយបើមានការខុសឆ្គងអ្វីមួយ សូមមេត្តាកុំប្រកែប្រកាន់អីឡើយ សូមប្រដៅខ្ញុំផង ព្រោះខ្ញុំពុំទាន់ដឹង ពុំទាន់ស្គាល់អំពីប្រពៃណី និងទំនៀមទម្លាប់ខ្មែរអស់ទេ !

ឮពាក្យសំដីរបស់ខ្ញុំ ប្តីប្រពន្ធម្ចាស់ផ្ទះនោះក៏ញញឹមដាក់គ្នា សំដែងសេចក្តីសប្បាយរីករាយ ។ ចំណែកខ្ញុំវិញ គ្រេកអរសប្បាយលើសគាត់រាប់រយដងទៅទៀត ពុំខុសពីមនុស្ស ដែលកំពុងលង់ទឹក ហើយមានគេជួយស្រោចស្រង់នោះទេ ! . .

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំក៏រស់នៅក្នុងគ្រួសារពូរ៉ុសដោយសុខក្សេមក្សាន្ត ។ សមាជិកក្នុងគ្រួសារទាំងអស់ គេពុំបានចាត់ទុកខ្ញុំជាជាឈ្នួលបម្រើទេ គឺស្រឡាញ់រាប់អានដូចក្នុងគ្រួសារតែមួយ ។ ពេលដែលខ្ញុំមកពុំទាន់ពេលអាស្រ័យបាយ ម្ចាស់ផ្ទះតែងតែចាប់ចំណីអាហា



គ្រប់ទុកដាក់ឲ្យយ៉ាងត្រឹមត្រូវ មិនតែប៉ុណ្ណោះ ញាតិមិត្តជិតខាងក៏ស្រឡាញ់រាប់អានខ្ញុំ គ្មានអ្នកណាស្អប់ខ្ពើមឡើយ ។

រស់នៅជិតគ្នាយូរទៅ ខ្ញុំនិងមាលា កាន់តែមានការស្និទ្ធស្នាលនឹងគ្នាខ្លាំងឡើង ៗ ជាលំដាប់ ។ ឥតុករបស់នាងប្រកបរបរធ្វើចិការផងនេសាទផង ។ គាត់តែងនាំខ្ញុំទៅនេសាទជាមួយជារៀងរាល់ពេល មិនយូរប៉ុន្មាន ខ្ញុំក៏ចេះថែទូក ចេះវាយសន្ទូច វាយមងស្ទាក់ចាំទាញជួនគេជួនឯង ។ ឃើញដូច្នោះ ពេលខ្លះដែលគាត់មានការរវល់ ឬជាប់ថែដំណាំពូរ៉ុសក៏បណ្តោយឲ្យខ្ញុំទៅវាយមងជាមួយមាលាតែពីរនាក់ ។ បន្ទាប់ពីបានត្រីមក ជួនកាលមាលាទៅលក់នៅភ្នំពេញជាមួយម្តាយ ជួនកាលមីងបែបឲ្យខ្ញុំទៅលក់តែពីរនាក់នឹងកូនក្រមុំរបស់គាត់ ។ ពេលត្រីអស់ហើយខ្ញុំនិងមាលាបណ្តើរគ្នាចូលផ្សារទិញរបស់របរ ឬម្ហូបអាហារតាមសេចក្តីត្រូវការយកមកផ្ទះវិញ យូរ ៗ ទៅចាស់ ៗ ទុកចិត្តមែនទែន យើងទាំងពីរនាក់ទៅណាមកណាមិនដែលឃ្លាតគ្នាសោះ ប្រៀបបីដូចជាលលកញីឈ្មោល ។

ចំណែកកម៉ានជាកូនប្រុសរបស់ពូរ៉ុស ពេលណាឃើញខ្ញុំមកនៅ វាតែងតែមកអង្គុយប្រកៀកខ្ញុំ ហើយដេកសួរអំពីស្ថានភាព និង ការរស់នៅរបស់ប្រជាជនឡាវ ធ្វើហាក់ដូចជាអ្នកសិក្សាស្រាវជ្រាវម្នាក់អ៊ីចឹង។ រូបសេចក្តីទៅ គឺគ្រួសារពូរ៉ុសសុទ្ធតែមានចិត្តមេត្តាករុណាចំពោះខ្ញុំទាំងចាស់ទាំងក្មេង ។

ការទាក់ទងស្និទ្ធស្នាលរវាងខ្ញុំនិងមាលា បើថាក្នុងលក្ខណៈជាបង

ប្អូនក៏ពុំត្រូវ បើថាក្នុងលក្ខណៈជាមិត្តភក្តិក៏ពុំសម ព្រោះនិ ពេលណាជាត់មុខនាង ខ្ញុំហាក់ចេះតែរសាប់រសល់ក្នុងខ្លួនទៅពុំសុខ ។ ចំណែកនាងវិញក៏អ៊ីចឹងដែរ ជាត់មុខខ្ញុំ នាងក៏តែងតែស្ទាក់មករុកជួបមុខដោយគ្មានហេតុផលដែរ ។

ពេលខ្លះ ខ្ញុំចេះតែសញ្ជឹងគិតងឿងឆ្ងល់ម្នាក់ឯងថា តើហេតុអ្វីបានជាខ្ញុំចង់តែទៅជិតមាលា ចង់តែឃើញមុខនាងយ៉ាងនេះ ! . . .

រហូតដល់ថ្ងៃមួយ ទើបខ្ញុំអាចរកឃើញចម្លើយបញ្ហានេះបាន គឺនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ ។ ព្រឹកនោះ ម៉ែងហែមបានរៀបចំបាយម្ហូបនិងនំចំណី ដើម្បីទៅវត្តអារាធនាតាមប្រពៃណីព្រះពុទ្ធសាសនា ហើយគាត់បានបង្គាប់ឲ្យមាលានិងខ្ញុំស្លៀកពាក់ឲ្យបានតែងខ្លួនទៅជាមួយគាត់ដែរ ព្រោះគាត់ចង់ឲ្យខ្ញុំឃើញទំនៀមបុណ្យប្រពៃណីខ្មែរ ។

នៅដល់វត្ត ម៉ែងហែមឡើងទៅលើសាលាឆាន់សុំសីលតាមប្រពៃណី។ ខ្ញុំ និង មាលា នាំគ្នាដើរលេងក្នុងធ្លាអារាមជាមួយនឹងយុវជន យុវនារីដែលគេគាត់ពួកចុះឡើងៗ ។ ហាក់ដូចជាភ្លេចពេលបន្តួចសម្រស់ជាតិគ្នាទៅវិញទៅមកអ៊ីចឹង ។

នៅក្នុងវិហារ មានយុវជន យុវនារីមួយក្រុមដែលនៅភូមិជាមួយកំពុងប្រជុំគ្នានិយាយលេងសើចក្អាកក្អាយ ។

លេចមុខយើងទាំងពីរនាក់ទៅដល់ភ្លាមពួកគេហៅឲ្យចូល ហើយមាននារីខ្លះសរសើរថា មាលាតែងខ្លួនទៅស្អាតដូចតំនួរ ។ បន្ទាប់មកម្នាក់និយាយពីនេះ ម្នាក់និយាយពីនោះ ខ្លះសើច ខ្លះប្រឡែងគ្នាព្រហើង



ភឹងកង ។ នារីម្នាក់ឈ្មោះនី សម្លឹងមុខមាលាសើចតិចៗ ហើយងាកមកសួរខ្ញុំ :

- បងបូផាច់ ប្រាប់ឲ្យត្រង់មកមើល៍ នារីបារាំងនិងនារីខ្មែរ នរណាស្អាតជាង ! . . .

ពួកគេទាំងអស់គ្នាបញ្ឈប់សំណើច និងពាក្យផ្លេះផ្លូកស្ងាត់ឈឹងភ្លាម ហើយនាំគ្នារង់ចាំស្តាប់ចម្លើយពីខ្ញុំ ។ ខ្ញុំសើចញញឹមមើលមុខមាលាបន្តិច ទើបឆ្លើយ :

- នារីខ្មែរ ស្អាតជាងនារីបារាំង ! . . .

នីទន្ទឹងរើស ប្រកែកមិនម៉ឺក :

- គ្មានទេ . . . កុំជឿបងបូផាច់បញ្ឆោតយើងហើយ តាមការពិតនារីបារាំងស្អាតជាងនារីខ្មែរ ! . . .

- រីឯណាឃើញនារីបារាំងពីរនាក់ ? . . . ( ខ្ញុំសួរវិញ )

ឮដូច្នោះ អ្នកឯទៀតក៏ហៅរកព្រៀវទាំងអស់គ្នា ព្រោះឃើញនីឆ្លើយពុំរួច ។ ការព្រោកព្រាតសប្បាយរីករាយក៏បន្តទៅទៀតព្រមគ្នាទាំងអស់ ប៉ុន្តែបន្ទាប់មក ស្រាប់តែឃើញយុវជនម្នាក់ដើរចូលមក មាលាក៏ស្រែកហៅយ៉ាងស្និទ្ធស្នាល :

- បងសម ! . . .

យុវជនចំណាំលង្វឹសើច និយាយគួរសមជាមួយយុវជននិងយុវនារីក្បែរៗខ្លួនបន្តិច ក៏ធ្វើសញ្ញាហៅមាលាឲ្យទៅជាមួយខ្លួន ។ សមនឹងមាលាដើរទៅឈរនិយាយគ្នាក្បែរជើងព្រះវិហារតែពីរ ។ រកតែអ្នកដទៃ

ស្លាប់ពុំបាន ប៉ុន្តែក្រោយពីខ្ញុំគ្មានអ្នកណាយកចិត្តទុកដាក់តាមដានសកម្មភាព នេះទេ ។

ឃើញដូច្នោះមិនដឹងជាមូលហេតុអី បានជាខ្ញុំរេះរោលក្នុងចិត្តប្រៀប ដូចអណ្ដាតភ្លើងឆេះឆាបឆេះពេញទ្រូងដោយក្ដីច្រណែន ។ ហេតុទ្រាំពុំបាន ក៏លួចដកខ្លួនដើរចេញពីគេឯងទាំងឈឺចាប់ខ្លោចផ្សារកស្មានពុំត្រូវ ។

មកដល់ផ្ទះ ខ្ញុំទាត់សំបកកំប៉ុងទឹកដោះគោមួយដែលនៅលើដីប៉ើង ធ្លាក់ទៅក្នុងទន្លេភ្លុងដើម្បីបន្ធូរកំហឹង ទើបដើរទៅប្រះខ្លួននៅក្នុងអង្រឹង ក្រនៅដែលចងខ្សែខ្វែងនឹងសសរផ្ទះ ។

មេឃមិស្រទុំ រលឹមផ្សែងក្រចរោយរាយនាំមកនូវធាតុត្រជាក់ ប៉ុន្តែ ក្នុងចិត្តខ្ញុំកំពុងតែក្ដៅដូចភ្នំភ្លើងផ្ទុះ ។ ខ្ញុំចេះតែចោទសួរខ្លួនឯងក្នុងខួរក្បាល ថា ៖ « ហេតុអីក៏ថ្ងៃនេះ មាលាមានអាកប្បកិរិយាចម្លែកម្ល៉េះ ! . . . តើ សមនេះជានរណា ? . . . ហេតុអីពេលជួបសម មាលាដើរចេញពីខ្ញុំអត់ ប្រាប់ខ្ញុំមួយម៉ាត់សោះ ហើយទៅឡើបឡៀវជាមួយគេពីចឹង !. ឬមួយគេ ទាំងពីរនាក់ជាសង្សារនឹងគ្នា » ។ គិតដល់ត្រង់នេះ ខ្ញុំទទួលអារម្មណ៍ ហាក់ដូចជាស្រងេះស្រងោចចំពោះជីវិតអនាគតរបស់ខ្លួន ។ ការតក់ក្ដៅ ដែលខ្ញុំមានពីប៉ុន្មានម៉ោងមុននេះ ឥឡូវត្រូវរលាយបាត់បង់អស់រលីង ហើយត្រូវជំនួសវិញដោយភាពកំព្រាឯកា ។

គិតយូរទៅ កាន់តែក្ដៅក្រហាយដោយមិនគួរល្ងង់ខ្លៅយល់ច្រឡំ ថា មាលាពេញចិត្តនឹងខ្លួនឯងទាល់តែសោះ ព្រោះខ្ញុំជាអ្នកក្រីក្រមក ជ្រកកោនក្នុងគ្រួសារនាង ។ ប៉ុន្តែបើនាងមានសង្សាររួចហើយ ហេតុអី



តាំងពីស្គាល់គ្នាថ្ងៃដំបូងមក នាងសំដែងអាការៈស្និទ្ធស្នាលបន្តិចម្ដង ៗ រហូតធ្វើឲ្យខ្ញុំដាក់ចិត្តដកពុំរួចយ៉ាងនេះ ? . . .

មកដល់ពេលនេះ ទើបខ្ញុំយល់ច្បាស់ខ្លួនឯងថា « ខ្ញុំស្រឡាញ់ មាលា » ។ ការរស់នៅជិតស្និទ្ធនឹងគ្នាតាំងពីយូរមកហើយនោះ វាមិន បានបង្កើតនូវចំណងមិត្តភាពទេ គឺវាបានសាងនូវចំណងស្នេហ៍ដ៏រឹងមាំ ដែលពុំងាយនឹងកាត់ផ្ដាច់បានទៅវិញ ។

*

* *